ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**
លេខ ០០៨/២៥ ន. គ. ស/សរ.ង.សា.

# សេចក្តីជូនដំណឹង
## ស្តីពី
## ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ សម្រាប់សហគ្រាសធុនតូចនិងមធ្យម កំណែប្រែលើកទី៣ ចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ

និយ័តករគណនេយ្យនិងសវនកម្ម មានកិត្តិយសសូមជម្រាបជូនដំណឹងដល់គ្រប់សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ គណនេយ្យករ សវនករ និងសាធារណជនទូទៅ ឱ្យបានជ្រាបថា៖ នាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៥ ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ ( International Accounting Standards Board ) ដែលជាស្ថាប័នឯករាជ្យក្នុងការអភិវឌ្ឍ និងអនុម័តលើស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ បានចេញផ្សាយនូវស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម កំណែប្រែលើកទី៣។

ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម កំណែប្រែលើកទី៣ នឹងចូលជាធរមានចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៧ តទៅ ជាមួយនឹងការលើកទឹកចិត្តឱ្យអនុវត្តមុនកាលបរិច្ឆេទកំណត់នេះបាន។

សម្រាប់ព័ត៌មានលម្អិត សូមចូលទៅកាន់គេហទំព័ររបស់និយ័តករ៖ www.acar.gov.kh និង IFRS Foundation៖ www.ifrs.org ។

អាស្រ័យហេតុនេះ សូមសហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ គណនេយ្យករ សវនករ និងសាធារណជនទូទៅ ជ្រាបជាព័ត៌មាន និងត្រូវត្រៀមលក្ខណៈឱ្យបានរួចរាល់សម្រាប់ការអនុវត្តស្តង់ដានេះនៅកម្ពុជាតាមកាលបរិច្ឆេទកំណត់ខាងលើ។

ថ្ងៃព្រហ. ១៥កើត ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មីនា គ.ស. ២០២៥
**និយ័តករគណនេយ្យនិងសវនកម្ម**

សូមស្កេន QR Code ដើម្បីទាញយកឯកសារ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ ០៩៥ - ២៣ ៨៨២ ១១១
Phone: 023 882 111